រាជរដ្ឋាភិបាលកម្ពុជា

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

# ប្លង់មេរៀន

## សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹង សុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

ខែកញ្ញា ឆ្នាំ២០១០

354.968
ACT-COM

NCDD Library
000415

# មាតិកា


កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល ........ ០១

ប្លង់មេរៀនទី ១ : សុខភាពមាតា ........ ០៦

ប្លង់មេរៀនទី ២ : អនាម័យ ........ ១២

ប្លង់មេរៀនទី ៣ : មត្តេយ្យសិក្សាសហគមន៍ ........ ១៤

ប្លង់មេរៀនទី ៤ : សមភាពយេនឌ័រ ........ ១៩

ប្លង់មេរៀនទី ៥ : កិច្ចការពារកុមារ ........ ២៤

ប្លង់មេរៀនទី ៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម ........ ២៩

ប្លង់មេរៀនទី ៧ : តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់ ........ ៣៧

ប្លង់មេរៀនទី ៨ : តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត ........ ៤១

# កម្មវិធីបណ្តុះបណ្តាល ស្តីពី
# សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹង សុខភាពមាតា អនាម័យ
# មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

ក្រុមទី១ :ថ្ងៃទី១៣_១៥ និងថ្ងៃទី១៦_១៨ ខែកញ្ញា ឆ្នាំ២០១០ សាលប្រជុំស្ទឹង សង្កែ សណ្ឋាគារស្ទឹង សង្កែ ខេត្តបាត់ដំបង

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| | **ថ្ងៃទី១** | |
| ០៧:៣០-០៨:០០ | ការអញ្ជើញមកដល់របស់សិក្ខាកាម | លោកស្រី ការប៊ុត សុមឡា/ឯក រិទ្ធី |
| ០៨:០០-០៨:៣០ | កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល | លោក ឈិន សេងងួន |
| ០៨:៣០-០៩:៣០ | មេរៀនទី១ : សុខភាពមាតា | លោកស្រី សឿន សាវី/ជេដ្ឋ គីមជុង |
| ០៩:៣០-០៩:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ០៩:៤៥-១០:៣០ | មេរៀនទី១ : សុខភាពមាតា (ត) | លោកស្រី សឿន សាវី/ជេដ្ឋ គីមជុង |
| ១០:៣០-១២:០០ | មេរៀនទី២ : អនាម័យ | លោក មិន ស៊ីថា |
| ១២:០០-១៤:០០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៤:០០-១៤:១០ | ការលេងល្បែងថាមពល | |
| ១៤:១០-១៥:៣០ | មេរៀនទី៣ : មត្តេយ្យសិក្សាសហគមន៍ | លោកស្រី យឹម ចាន់ស្រី/សំ មនោរម្យ |
| ១៥:៣០-១៥:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ១៥:៤៥-១៧:៣០ | មេរៀនទី៤ : សមភាពយេនឌ័រ | លោកស្រី គីម ស៊ីផាត់/ទូច គីមឆាន |
| | **ថ្ងៃទី២** | |
| ០៧:៣០-០៧:៥០ | រំលឹកមេរៀនថ្ងៃទី១ | |
| ០៧:៥០-០៨:៥០ | មេរៀនទី៤ : សមភាពយេនឌ័រ (ត) | លោកស្រី គីម ស៊ីផាត់/ទូច គីមឆាន |
| ០៨:៥០-០៩:៣០ | មេរៀនទី៥ : កិច្ចការពារកុមារ | លោក តូច ចាន់នី/មិន ស៊ីថា |
| ០៩:៣០-០៩:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ០៩:៤៥-១២:០០ | មេរៀនទី៥ : កិច្ចការពារកុមារ (ត) | លោក តូច ចាន់នី/មិន ស៊ីថា |
| ១២:០០-១៤:០០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៤:០០-១៤:១៥ | ការលេងល្បែងថាមពល | |
| ០៤:១៥-១៥:០៥ | មេរៀនទី៥ : កិច្ចការពារកុមារ (ត) | លោក តូច ចាន់នី/មិន ស៊ីថា |
| ១៥:០៥-១៥:៣០ | មេរៀនទី៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍ ផ្នែកសង្គម | លោក ជេដ្ឋ គីមជុង |
| ១៥:៣០-១៥:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ១៥:៤៥-១៧:៣០ | មេរៀនទី៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍ ផ្នែកសង្គម (ត) | លោក សំ មនោរម្យ |

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
| --- | --- | --- |
| | ថ្ងៃទី៣ | |
| ០៧:៣០-០៧:៤០ | រំលឹកមេរៀនថ្ងៃទី២ | |
| ០៧:៤០-០៩:៣០ | មេរៀនទី៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម(ត) | លោក សេត សាម៉ន/សំ មនោរម្យ |
| ០៩:៣០-០៩:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ០៩:៤៥-១០:១៥ | មេរៀនទី៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍ ផ្នែកសង្គម(ត) | លោកស្រី គីម ស៊ីផាត់/មិន ស៊ីថា |
| ១០:១៥-១២:០០ | មេរៀនទី៧ : តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ នៅថ្នាក់ឃុំ សង្កាត់ | លោក ជេដ្ឋ គីមជុង |
| ១២:០០-១៤:០០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៤:០០-១៤:១៥ | ការលេងល្បែងថាមពល | |
| ១៤:១៥-១៤:៤០ | មេរៀនទី៧ : តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ នៅថ្នាក់ឃុំ សង្កាត់ | លោក ជេដ្ឋ គីមជុង |
| ១៤:៤០-១៥:៣០ | មេរៀនទី៨ : តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធ នៅថ្នាក់រាជធានី ខេត្ត | លោក ទូច គីមឆាន |
| ១៥:៣០-១៥:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ១៥:៤៥-១៧:១០ | មេរៀនទី៨ : តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធ នៅថ្នាក់រាជធានី ខេត្ត | លោក ទូច គីមឆាន |
| ១៧:១០-១៧:៣០ | បិទវគ្គបណ្តុះបណ្តាល | លោក ឈិន សេងងួន |

# កិច្ចចាប់ផ្ដើមនៃវគ្គបណ្ដុះបណ្ដាល

# កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល

មុននឹងចូលដល់មេរៀនទី១ អ្នកសម្របសម្រួលអនុវត្តសកម្មភាពមួយចំនួនខាងក្រោម :

១. ការណែនាំឱ្យស្គាល់គ្នា
២. បង្ហាញគោលបំណង និងលទ្ធផលរំពឹងទុកនៃវគ្គបណ្តុះបណ្តាល
៣. វិន័យសម្រាប់វគ្គបណ្តុះបណ្តាល
៤. ក្រុមគាំទ្រដល់ការបណ្តុះបណ្តាល ( ក្រុមល្បែងកំសាន្ត និងក្រុមរំលឹកមេរៀន....)
៥. កម្មវិធីបណ្តុះបណ្តាល
៦. ការវាយតម្លៃវគ្គបណ្តុះបណ្តាល
៧. ឯកសារបណ្តុះបណ្តាល ( ឯកសារមេរៀន និងប្លង់មេរៀន...)
៨. ការរៀបចំផ្សេងៗទៀត ដូចជា លិខិតបេសកកម្ម សេចក្តីជូនដំណឹងផ្សេងៗ ( បើមាន)

## ១. ការណែនាំឱ្យស្គាល់គ្នា (៥នាទី)

អ្នកសម្របសម្រួលអាចប្រើប្រាស់វិធីសាស្ត្រផ្សេងៗ ក្នុងការណែនាំឱ្យស្គាល់គ្នា ដើម្បីឱ្យស្គាល់ឈ្មោះ តួនាទី ទីកន្លែងធ្វើការងារ . . . ។ល។

## ២. ការបង្ហាញគោលបំណងនៃវគ្គបណ្តុះបណ្តាល និងការរំពឹងទុក

អ្នកសម្របសម្រួល បង្ហាញគោលបំណងនៃវគ្គបណ្តុះបណ្តាលដល់សិក្ខាកាម។ នៅចុងបញ្ចប់នៃវគ្គបណ្តុះបណ្តាលនេះ សិក្ខាកាមនឹងអាចយល់ដឹងអំពី :

– ស្ថានភាពសេវាសង្គមនៅឃុំ សង្កាត់
– សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម
– យន្តការគាំទ្រការអភិវឌ្ឍផ្នែកសង្គម

## ៣. វិន័យសម្រាប់វគ្គបណ្តុះបណ្តាល (៥នាទី)

អ្នកសម្របសម្រួលរួមជាមួយសិក្ខាកាមពិភាក្សាគ្នា ដើម្បីកំណត់វិន័យសម្រាប់វគ្គបណ្តុះបណ្តាល ដូចជាម៉ោងសិក្សា ( ម៉ោងចូល ម៉ោងចេញ និងម៉ោងសម្រាក) ការរំខានដោយសម្លេងទូរស័ព្ទ ការមកយឺតយ៉ាវ ។ល។

## ៤. សិក្ខាកាម (៥នាទី)

ការបណ្តុះបណ្តាលក្នុងមួយវគ្គៗ មានសិក្ខាកាមចូលរួមពី២៥ ទៅ៣០នាក់។ សិក្ខាកាមរួមមាន :

- **មន្ត្រីចូលរួមបណ្តុះបណ្តាលនៅថ្នាក់ជាតិ : ១៩២ នាក់ ក្នុងនោះ**
  – មន្ត្រីទីចាត់ការផែនការ និងវិនិយោគ ២៤រាជធានី ខេត្ត សរុប ៣៦ នាក់

  - ទីប្រឹក្សារដ្ឋបាលមូលដ្ឋាន ២៤រាជធានី ខេត្ត សរុប ៣៦ នាក់
  - មន្ទីរពាក់ព័ន្ធចំនួន៥ ( ១នាក់/១មន្ទីរ ) ២៤រាជធានី ខេត្ត សរុប ១២០ នាក់
- **ថ្នាក់រាជធានី ខេត្ត : ១៦៩១ នាក់ ក្នុងនោះមាន**
  - អ្នកសម្របសម្រួលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌទាំងអស់
  - មន្ទីរពាក់ព័ន្ធ ៥មន្ទីរ ១មន្ទីរចំនួន ២នាក់
- **ថ្នាក់ឃុំ សង្កាត់ :** សមាជិក គ.ក.ន.ក ចំនួន ១០នាក់ ក្នុងមួយឃុំ សង្កាត់

## ៥. ក្រុមគាំទ្រវគ្គបណ្តុះបណ្តាល (៥នាទី)

អ្នកសម្របសម្រួល ស្នើឱ្យសិក្ខាកាមស្ម័គ្រចិត្តៈ

- រំលឹកមេរៀន (២នាក់សម្រាប់មួយថ្ងៃ នៅពេលព្រឹកនៃថ្ងៃនីមួយៗ)
- លេងល្បែងកំសាន្ត (២នាក់សម្រាប់ ១ថ្ងៃ លេងល្បែង ១ដង)

## ៦. ឯកសារមេរៀន

ឯកសារមេរៀន និងប្លង់មេរៀនសម្រាប់ចែកសិក្ខាកាម :

- **ការបណ្តុះបណ្តាលគ្រូបង្គោលថ្នាក់ជាតិ :** ការបោះពុម្ព និងការចំណាយលើឯកសារមេរៀន និងប្លង់មេរៀនជាបន្ទុករបស់ថ្នាក់ជាតិ (គ.ជ.អ.ប)
- **ការបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ខេត្ត :** ការបោះពុម្ព និងការចំណាយលើឯកសារមេរៀន និងប្លង់មេរៀនជាបន្ទុករបស់ គ.ជ.អ.ប ថ្នាក់ជាតិ។ ចំនួនសៀវភៅដែលត្រូវផ្តល់ឱ្យមានចំនួនសរុបស្មើនឹងចំនួនសរុបនៃចំនួនអ្នកសម្របសម្រួលរាជធានី ខេត្តទាំងអស់ ទីប្រឹក្សារដ្ឋបាលមូលដ្ឋាន និងចំនួន ៥មន្ទីរ (២នាក់/មន្ទីរ)
- **ការបណ្តុះបណ្តាលនៅថ្នាក់ឃុំ សង្កាត់ :** ការបោះពុម្ព និងការចំណាយលើឯកសារមេរៀនជាបន្ទុករបស់ គ.ជ.អ.ប ថ្នាក់ជាតិ។ ចំនួនសៀវភៅដែលត្រូវផ្តល់ឱ្យមានចំនួនសរុបស្មើនឹងចំនួនឃុំ សង្កាត់ គុណនឹង ១០ (១០ក្បាលក្នុងមួយឃុំ សង្កាត់)។

## ៧. កម្មវិធីបណ្តុះបណ្តាល (៥នាទី)

អ្នកសម្របសម្រួលបង្ហាញកម្មវិធីបណ្តុះបណ្តាល និងចែកកម្មវិធីបណ្តុះបណ្តាលដល់សិក្ខាកាម ។

## ៨. ការវាយតម្លៃវគ្គបណ្តុះបណ្តាល (៥នាទី)

ការវាយតម្លៃវគ្គបណ្តុះបណ្តាលត្រូវអនុវត្តតាមវិធីដូចខាងក្រោមៈ

អ្នកសម្របសម្រួលចែកតារាងវាយតម្លៃវគ្គបណ្តុះបណ្តាល និងពន្យល់អំពីរបៀបបំពេញទម្រង់វាយតម្លៃ និងរំលឹកដល់សិក្ខាកាមឱ្យបំពេញទម្រង់វាយតម្លៃបន្ទាប់ពីបញ្ចប់មេរៀននីមួយៗ។

## កម្មវិធីបណ្តុះបណ្តាល ស្តីពី សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹង សុខភាពមាតា អនាម័យ មគ្គុទ្ទេសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| ថ្ងៃទី១ | | |
| ០៧:៣០-០៨:០០ | ការអញ្ជើញមកដល់របស់សិក្ខាកាម | |
| ០៨:០០-០៨:៣០ | កិច្ចចាប់ផ្តើមនៃវគ្គបណ្តុះបណ្តាល | |
| ០៨:៣០-០៩:៣០ | មេរៀនទី១ : សុខភាពមាតា | |
| ០៩:៣០-០៩:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ០៩:៤៥-១០:០៥ | មេរៀនទី១ : សុខភាពមាតា (ត) | |
| ១០:០០-១០:៥០ | មេរៀនទី២ : អនាម័យ | |
| ១០:៥០-១២:០០ | មេរៀនទី៣ : មគ្គុទ្ទេសិក្សាសហគមន៍ | |
| ១២:០០-១៤:០០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៤:០០-១៤:១៥ | ការលេងល្បែងថាមពល | |
| ១៤:១៥-១៥:៣០ | មេរៀនទី៣ : មគ្គុទ្ទេសិក្សាសហគមន៍ | |
| ១៥:៣០-១៥:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ១៥:៤៥-១៧:៣០ | មេរៀនទី៤ : សមភាពយេនឌ័រ | |
| ថ្ងៃទី២ | | |
| ០៧:៣០-០៧:៥០ | រំលឹកមេរៀនថ្ងៃទី១ | |
| ០៧:៥០-០៨:៥០ | មេរៀនទី៤ : សមភាពយេនឌ័រ (ត) | |
| ០៨:៥០-០៩:៣០ | មេរៀនទី៥ : កិច្ចការពារកុមារ | |
| ០៩:៣០-០៩:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ០៩:៤៥-១២:០០ | មេរៀនទី៥ : កិច្ចការពារកុមារ (ត) | |
| ១២:០០-១៤:០០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៤:០០-១៤:១៥ | ការលេងល្បែងថាមពល | |
| ០៤:១៥-១៥:០៥ | មេរៀនទី៥ : កិច្ចការពារកុមារ (ត) | |
| ១៥:០៥-១៥:៣០ | មេរៀនទី៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម | |
| ១៥:៣០-១៥:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ១៥:៤៥-១៧:៣០ | មេរៀនទី៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម (ត) | |

| ពេលវេលា | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| ថ្ងៃទី៣ | | |
| ០៧:៣០-០៧:៥០ | រំលឹកមេរៀនថ្ងៃទី២ | |
| ០៧:៥០-០៩:៣០ | មេរៀនទី៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម (ត) | |
| ០៩:៣០-០៩:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ០៩:៤៥-១០:១៥ | មេរៀនទី៦ : សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម (ត) | |
| ១០:១៥-១២:០០ | មេរៀនទី៧ : តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់ | |
| ១២:០០-១៤:០០ | សម្រាកអាហារថ្ងៃត្រង់ | |
| ១៤:០០-១៤:១៥ | ការលេងល្បែងថាមពល | |
| ១៤:១៥-១៤:៤០ | មេរៀនទី៧ : តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់ | |
| ១៤:៤០-១៥:៣០ | មេរៀនទី៨ : តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត | |
| ១៥:៣០-១៥:៤៥ | សម្រាកពិសាអាហារសម្រន់ | |
| ១៥:៤៥-១៧:១០ | មេរៀនទី៨ : តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត | |
| ១៧:១០-១៧:៣០ | បិទវគ្គបណ្ដុះបណ្ដាល | |

# តារាងវាយតម្លៃ វគ្គបណ្តុះបណ្តាល ស្តីពី

## សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គមពាក់ព័ន្ធនឹងសុខភាពមាតា អនាម័យ មគ្គុទ្ទេសក៍សិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ

| មេរៀន | ខ្លឹមសារមេរៀន | | | | | | | | | | ការសម្របសម្រួល | | | | | | | | | | លំហាត់ និងការអនុវត្ត | | | | | | | | | | ពេលវេលា | | | | | | | | | | កម្រិតយល់ដឹងរបស់សិក្ខាកាម | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 | 1 | 2 | 3 | 4 | 5 | 6 | 7 | 8 | 9 | 10 |
| | អន់ | | | | | | | | | ល្អ | អន់ | | | | | | | | | ល្អ | អន់ | | | | | | | | | ល្អ | អន់ | | | | | | | | | ល្អ | អន់ | | | | | | | | | ល្អ |
| 1 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 2 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 3 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 4 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 5 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 6 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 7 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |
| 8 | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | | |

**មតិយោបល់ផ្សេងៗ (Other Comments)**

# ប្លង់មេរៀនទី១

# សុខភាពមាតា

# ប្លង់មេរៀនទី១

# សុខភាពមាតា

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច :<br>– កំណត់ទីកន្លែងដែលអាចផ្តល់សេវាថែទាំសុខភាពមាតា និងទារកនៅឃុំ សង្កាត់<br>– ពិពណ៌នាអំពីថែទាំសុខភាពមាតា និងទារក<br>– ពិពណ៌នាអំពីអាហារូបត្ថម្ភ |
| រយៈពេលសរុប | ៨៥នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឹត ស្កុត មេរៀន ១.១ និងលំហាត់ទី១ |
| វិធីសាស្ត្រ | ការបំផុសគំនិត ក្រុមពិភាក្សា និងការបង្ហាញពន្យល់ |
| សកម្មភាពសម្របសម្រួលមេរៀន | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ០៥នាទី | **១. សេចក្តីផ្តើម**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា ក្នុងឆ្នាំ២០១០ ក្រុមប្រឹក្សាឃុំ សង្កាត់បានទទួលថវិកាពី គ.អ.ជ.ប ក្នុងការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គម ដូច្នេះការយល់ដឹងអំពីសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គមអាចជួយឃុំ សង្កាត់អនុវត្តមុខងារនេះមានប្រសិទ្ធភាព។ ផ្នែកសង្គមដែលលើកយកមកសិក្សានេះមាន សុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ។ | |
| ១០នាទី | **២. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរថា : **"តើប្រជាពលរដ្ឋអាចទទួលបានសេវាថែទាំសុខភាពរបស់រដ្ឋនៅទីណាខ្លះ?"** រួចផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្តងៗ ហើយអ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– មន្ទីរពេទ្យបង្អែក<br>– មណ្ឌលសុខភាព<br>– ប៉ុស្តិ៍សុខភាព<br>– ការផ្តល់សេវាចុះមូលដ្ឋាន | |

| រយៈពេល | សកម្មភាព | ធនធាន |
| --- | --- | --- |
| | បន្ទាប់មក អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរថា : **"តើប្រជាពលរដ្ឋអាចទទួលសេវាសុខភាពអ្វីខ្លះពីសេវាសុខភាពរដ្ឋទាំងនោះ?"** រួចផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្តងៗ ហើយអ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>- **ការការពារ** : ផ្តល់ថ្នាំបង្ការ ផ្តល់គ្រាប់ថ្នាំជីវជាតិអា ការផ្តល់គ្រាប់ថ្នាំជាតិដែក/អាស៊ីដហ្វូលិក ការពិនិត្យផ្ទៃពោះមុនពេលសម្រាល ការពន្យារកំណើត ពិនិត្យមើលបញ្ហាកង្វះអាហារូបត្ថម្ភ ការអប់រំសុខភាពមាតា និងទារក<br>- **ការថែទាំ និងព្យាបាល** : ការពិគ្រោះពិនិត្យ និងព្យាបាលជំងឺទូទៅ ជំងឺកាមរោគ ការវះកាត់តូច ការធ្វើតេស្តឈាម និងព្យាបាលជំងឺគ្រុនចាញ់ ការសម្រាលធម្មតា ព្យាបាលជំងឺរបេង ដោយប្រើប្រាស់ដូតស៍ សង្កេតជំងឺហង់សិន និងបញ្ជូនទៅផ្នែកសេវាសុខភាពពាក់ព័ន្ធ។<br>បន្ទាប់មក អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរថា : **"ដើម្បីត្រៀមជុំវិញកំណើត តើត្រូវធ្វើអ្វីខ្លះ?"** រួចផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្តងៗ ហើយអ្នកសម្របសម្រួលកត់ត្រា ចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>- ពិនិត្យផ្ទៃពោះយ៉ាងតិច២ដង ក្នុងអំឡុងពេលមានផ្ទៃពោះ<br>- ហូបចំណីអាហារចម្រុះឱ្យបានគ្រប់គ្រាន់ និងថ្នាំជាតិដែកបន្ថែមតាមវេជ្ជបញ្ជា<br>- ទទួលការណែនាំពីគ្រូពេទ្យអំពីអ្វីដែលមិនគួរធ្វើក្នុងពេលមានផ្ទៃពោះ ដូចជា សេពគ្រឿងស្រវឹង ជក់បារី និងការប្រើថ្នាំដោយពុំមានវេជ្ជបញ្ជា<br>- សន្សំប្រាក់សម្រាប់ទំនុកបម្រុងពេលសម្រាលកូន<br>- ត្រៀមបម្រុងមធ្យោបាយធ្វើដំណើរសម្រាប់បញ្ជូនទៅមណ្ឌលសុខភាព ពេលសម្រាលកូន<br>- សម្រាលកូនត្រូវសម្រាលដោយឆ្មបជំនាញនៅមណ្ឌលសុខភាព | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | – ទទួលការណែនាំពីគ្រូពេទ្យអំពីសារប្រយោជន៍នៃការបំបៅកូនដោយទឹកដោះម្ដាយ និងការចាក់ថ្នាំបង្ការ ។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលបំផុសគំនិតសូមពិនិត្យមេរៀនដូចខាងក្រោមបន្ទាប់មក អ្នកសម្របសម្រួលធ្វើការបង្ហាញខ្លឹមសារមេរៀន ចំណុច "១.១. សុខភាពមាតា "។ | |
| ២០នាទី | **៣. បង្ហាញ និងពន្យល់ខ្លឹមសារមេរៀន**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន **"១.១.១. សេវាសុខភាពនៅឃុំ សង្កាត់ និង ១.១.២. ការថែទាំសុខភាពមាតា និងទារក"**។ នៅចុងបញ្ចប់នៃការបង្ហាញ មេរៀននេះ សិក្ខាកាមត្រូវបានផ្ដល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលធ្វើការពន្យល់បំភ្លឺបន្ថែម ។ | ខ្លឹមសារមេរៀន ១.១.១ និង ១.១.២ |
| ១០នាទី | **៤. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតដោយសួរថា : **"តើអាហារូបត្ថម្ភមានន័យដូចម្ដេច?"** រួចផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្ដងៗ ហើយអ្នកសម្របសម្រួលកត់ត្រាចម្លើយទាំងលើក្រដាសផ្ទាំងធំ ។ ចម្លើយអាចមាន :<br>– អាហារូបត្ថម្ភ គឺជាសារធាតុមាននៅក្នុងចំណីអាហារ ដែលជួយដល់ការលូតលាស់រាងកាយ និងប្រាជ្ញាស្មារតីរបស់មនុស្ស ។<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតដោយសួរថា : **"ប្រជាពលរដ្ឋអាចទទួលបានអាហារូបត្ថម្ភពីប្រភពណាខ្លះ?"** រួចផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្ដងៗ ហើយអ្នកសម្របសម្រួលកត់ត្រាចម្លើយទាំងលើក្រដាសផ្ទាំងធំ ។ ចម្លើយអាចមាន :<br>– អាចទទួលបានអាហារូបត្ថម្ភ តាមរយៈការបរិភោគចំណីអាហារ ដូចជា សាច់ ស៊ុត ទឹកដោះ ផលិតផលទឹកដោះ ត្រី សណ្ដែកសៀង គ្រាប់ធញ្ញជាតិ បន្លែបៃតង និងផ្លែឈើ ។ល។<br>– អាចទទួលអាហារូបត្ថម្ភបន្ថែមពីមណ្ឌលសុខភាពផងដែរ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ដូចជា គ្រាប់ថ្នាំជីវជាតិអា គ្រាប់ថ្នាំជីវជាតិដែក ។ល។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលបំផុសគំនិតសូមពិនិត្យមេរៀនដូចខាងក្រោម បន្ទាប់មក អ្នកសម្របសម្រួលធ្វើការបង្ហាញខ្លឹមសារមេរៀន ចំណុច "១.១. សុខភាពមាតា " (ត)។ | |
| ១០នាទី | **៥. បង្ហាញ និងពន្យល់ខ្លឹមសារមេរៀន**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន "**១.១.៣.ការផ្តល់អាហារូបត្ថម្ភ**"។ នៅចុងបញ្ចប់នៃការបង្ហាញមេរៀននេះ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលធ្វើការពន្យល់បំភ្លឺបន្ថែម។ | ខ្លឹមសារមេរៀន ១.១.៣ |
| ៣០នាទី | **៦. ការពិភាក្សាក្រុមតូច**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា រួចចែកសិក្ខាកាមជាក្រុមតូចៗ ២នាក់ទៅ៣នាក់ ក្នុង១ក្រុម ដែលអង្គុយជិតៗគ្នា រួចចែកក្រដាសលំហាត់ទី១ ដោយ១ក្រុម ១ច្បាប់។ រយៈពេលពិភាក្សា ១៥ នាទី។<br>បន្ទាប់ពីចប់ការពិភាក្សា អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យក្រុមនីមួយៗបង្ហាញចម្លើយរបស់ក្រុមខ្លួន ដោយផ្តល់ឱ្យអ្នកឆ្លើយថា "ពិត" លើកដៃ។ បន្ទាប់មក អ្នកសម្របសម្រួល ផ្តល់ចម្លើយត្រឹមត្រូវដល់សិក្ខាកាម រួចធ្វើបែបនេះជាបន្តបន្ទាប់ រហូតដល់ចប់។ | ក្រដាសលំហាត់ទី១ |

## លំហាត់ទី១ ការពិភាក្សាក្រុមតូច

ចូរបញ្ជាក់ថា ការពិពណ៌នាខាងក្រោមនេះពិត ឬមិនពិត ដោយគូសសញ្ញា ✓ នៅក្នុងកូឡោនពិត ឬមិនពិត ។

| | ការពិពណ៌នា | ពិត | មិនពិត |
|---|---|---|---|
| ១. | ការបង្កើតមន្ទីរពេទ្យបង្អែក ផ្អែកតាមចំនួនប្រជាពលរដ្ឋចំនួន ៦០.០០០នាក់ ទៅ ២០០.០០០នាក់ ។ | | |
| ២. | ការបង្កើតមណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ផ្អែកតាមចំនួនប្រជាពលរដ្ឋចំនួន៨.០០០នាក់ ទៅ ១២.០០០នាក់ ។ | | |
| ៣. | ការត្រៀមជុំវិញកំណើត ជាបញ្ហារបស់ស្ត្រីមានផ្ទៃពោះម្នាក់ឯងតែប៉ុណ្ណោះ ហេតុនេះ ក្រុមគ្រួសារ និងស្វាមីពុំមានតួនាទី និងការងារអ្វីពាក់ព័ន្ធឡើយ ។ | | |
| ៤. | ការសម្រាលត្រូវធ្វើឡើងជាមួយពេទ្យឆ្មបជំនាញដែលបានទទួលការបណ្តុះបណ្តាលរួច ។ ប្រសិនបើមិនអាចរកពេទ្យឆ្មបជំនាញដែលបានទទួលការបណ្តុះបណ្តាលបានអាចជំនួស ដោយសេវាឆ្មបបុរាណដែលមិនបានឆ្លងកាត់ការបណ្តុះបណ្តាលបាន ។ | | |
| ៥. | ស្ត្រីមានផ្ទៃពោះមិនត្រូវសន្សំប្រាក់សម្រាប់ទំនុកបម្រុងពេលសម្រាលកូន និងបម្រុងមធ្យោបាយធ្វើដំណើរសម្រាប់បញ្ជូនទៅមណ្ឌលសុខភាព ពេលមានបញ្ហា ឬពេលសម្រាលកូន ។ | | |
| ៦. | ស្ត្រីមានផ្ទៃពោះអាចទទួលទានគ្រប់បែបយ៉ាងរួមទាំង សេពគ្រឿងស្រវឹង ជក់បារី និង ការប្រើថ្នាំដោយពុំចាំបាច់មានវេជ្ជបញ្ជាផងដែរ ។ | | |
| ៧. | ទឹកដោះម្តាយតែមួយមុខ គឺជាអាហារនិងទឹកដែលទារកត្រូវការ ។ បន្ទាប់ពី៦ខែ ទារក ចាំបាច់ត្រូវការអាហារបន្ថែមពីលើទឹកដោះម្តាយ ។ | | |
| ៨. | ទារក និងកុមារដែលមានអាយុ១ខែកន្លះ, អាយុ២ខែកន្លះ, អាយុ៣ខែកន្លះ ត្រូវទទួលថ្នាំបង្ការ ការពារជំងឺគ្រុនស្វិតដៃជើង ជំងឺក្អកមាន់ ខាន់ស្លាក់ តេតាណូស ជំងឺរលាកថ្លើមប្រភេទបេ និងជំងឺហ៊ីប | | |
| ៩. | កុមារមិនបានទទួលជាតិ អ៊ីយ៉ូដគ្រប់គ្រាន់ ឬម្តាយខ្វះជាតិអ៊ីយ៉ូដពេលមានផ្ទៃពោះកូនកើត ពុំអាចពិការភាពខាងស្មារតី ការស្តាប់ និងការនិយាយ ឬធ្វើឱ្យការលូតលាស់ផ្នែកផ្លូវកាយ និង ផ្លូវចិត្តមានការយឺតយ៉ាវ ។ | | |
| ១០. | ការប្រើប្រាស់អំបិលលាយអ៊ីយ៉ូដជំនួសអំបិលធម្មតាអាចឱ្យម្តាយ និងកូនមានជាតិអ៊ីយ៉ូដ គ្រប់គ្រាន់តាមសេចក្តីត្រូវការ ។ | | |

## ចម្លើយសម្រាប់លំហាត់ទី១

ចូរបញ្ជាក់ថា ការពិពណ៌នាខាងក្រោមនេះពិត ឬមិនពិត ដោយគូសសញ្ញា ✓ នៅក្នុងកូឡោនពិត ឬមិនពិត ។

| | ការពិពណ៌នា | ពិត | មិនពិត |
|---|---|---|---|
| ១. | ការបង្កើតមន្ទីរពេទ្យបង្អែក ផ្អែកតាមចំនួនប្រជាពលរដ្ឋចំនួន ៦០.០០០នាក់ ទៅ ២០០.០០០នាក់ ។ | ✓ | |
| ២. | ការបង្កើតមណ្ឌលសុខភាព និងប៉ុស្តិ៍សុខភាព ផ្អែកតាមចំនួនប្រជាពលរដ្ឋចំនួន៨.០០០នាក់ ទៅ ១២.០០០នាក់ ។ | | ✓ |
| ៣. | ការត្រៀមជុំវិញកំណើត ជាបញ្ហារបស់ស្ត្រីមានផ្ទៃពោះម្នាក់ឯងតែប៉ុណ្ណោះ ហេតុនេះ ក្រុមគ្រួសារ និងស្វាមីពុំមានតួនាទី និងការងារអ្វីពាក់ព័ន្ធឡើយ ។ | | ✓ |
| ៤. | ការសម្រាលត្រូវធ្វើឡើងជាមួយពេទ្យឆ្មបជំនាញដែលបានទទួលការបណ្តុះបណ្តាលរួច ។ ប្រសិនបើមិនអាចរកពេទ្យឆ្មបជំនាញដែលបានទទួលការបណ្តុះបណ្តាលបានអាចជំនួស ដោយសេវាឆ្មបបុរាណដែលមិនបានឆ្លងកាត់ការបណ្តុះបណ្តាលបាន ។ | | ✓ |
| ៥. | ស្ត្រីមានផ្ទៃពោះមិនត្រូវសន្សំប្រាក់សម្រាប់ទំនុកបម្រុងពេលសម្រាលកូន និងបម្រុងមធ្យោបាយធ្វើដំណើរសម្រាប់បញ្ជូនទៅមណ្ឌលសុខភាព ពេលមានបញ្ហា ឬពេលសម្រាលកូន ។ | | ✓ |
| ៦. | ស្ត្រីមានផ្ទៃពោះអាចទទួលទានគ្រប់បែបយ៉ាងរួមទាំង សេពគ្រឿងស្រវឹង ជក់បារី និង ការប្រើថ្នាំដោយពុំចាំបាច់មានវេជ្ជបញ្ជាផងដែរ ។ | | ✓ |
| ៧. | ទឹកដោះម្តាយតែមួយមុខ គឺជាអាហារនិងទឹកដែលទារកត្រូវការ ។ បន្ទាប់ពី៦ខែ ទារក ចាំបាច់ត្រូវការអាហារបន្ថែមពីលើទឹកដោះម្តាយ ។ | ✓ | |
| ៨. | ទារក និងកុមារដែលមានអាយុ១ខែកន្លះ, អាយុ២ខែកន្លះ, អាយុ៣ខែកន្លះ ត្រូវទទួលថ្នាំបង្ការ ការពារជំងឺគ្រុនស្វិតដៃជើង ជំងឺក្អកមាន់ ខាន់ស្លាក់ តេតាណូស ជំងឺរលាកថ្លើមប្រភេទបេ និងជំងឺហ៊ីប | ✓ | |
| ៩. | កុមារមិនបានទទួលជាតិ អ៊ីយ៉ូដគ្រប់គ្រាន់ ឬម្តាយខ្វះជាតិអ៊ីយ៉ូដពេលមានផ្ទៃពោះកូនកើត ពុំអាចពិការភាពខាងស្មារតី ការស្តាប់ និងការនិយាយ ឬធ្វើឱ្យការលូតលាស់ផ្នែកផ្លូវកាយ និងផ្លូវចិត្តមានការយឺតយ៉ាវ ។ | | ✓ |
| ១០ | ការប្រើប្រាស់អំបិលលាយអ៊ីយ៉ូដជំនួសអំបិលធម្មតាអាចឱ្យម្តាយ និងកូនមានជាតិអ៊ីយ៉ូដ គ្រប់គ្រាន់តាមសេចក្តីត្រូវការ ។ | ✓ | |

# ប្លង់មេរៀនទី២

# អនាម័យ

# ប្លង់មេរៀនទី២

# អនាម័យ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច :<br>– ពិពណ៌នាអំពីអត្ថន័យនៃអនាម័យ<br>– ពិពណ៌នាអំពីសារប្រយោជន៍នៃអនាម័យ<br>– កំណត់អំពីជំងឺមួយចំនួនដែលបណ្តាលមកពីខ្វះអនាម័យ |
| រយៈពេលសរុប | ៥០នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត មេរៀន១.២ លំហាត់ទី២ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញពន្យល់ និងពិភាក្សាក្រុមតូច |
| សកម្មភាពសម្របសម្រួលមេរៀន | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ០៥ នាទី | **១. សេចក្តីផ្តើម**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានសិក្សារួចហើយមេរៀន "*សុខភាពមាតា*" តើមេរៀននោះសិក្សាអំពីអ្វីខ្លះ? បន្ទាប់មក អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយ ឬ អ្នកសម្របសម្រួលផ្តល់ចម្លើយសង្ខេបតែម្តង ។ មេរៀននោះពិពណ៌នាអំពី :<br>– សេវាសុខភាពនៅឃុំ សង្កាត់<br>– ការថែទាំសុខភាពមាតា និងទារក<br>– ការផ្តល់អាហារូបត្ថម្ភ<br>នៅពេលបញ្ចប់ការសង្ខេបមេរៀននេះ អ្នកសម្របសម្រួលលើកឡើងថា ជាបន្តយើងចូលមេរៀនថ្មីមួយទៀតដែលសិក្សាអំពី "**អនាម័យ**" ។ | |
| ២០ នាទី | **២. ការពិភាក្សាក្រុមតូច**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា និងចែកសិក្ខាកាមដែលអង្គុយជិតៗគ្នាជាដៃគូ២នាក់ៗ និងចែកក្រដាសលំហាត់ទី២ ដោយ១ក្រុម ១ច្បាប់ ។ ការពិភាក្សាមានរយៈពេល១៥នាទី ។ ក្រុមនីមួយៗពិភាក្សាលើប្រធានបទ :<br>**១. តើអនាម័យមានន័យដូចម្តេច?** | ក្រដាស លំហាត់ទី២ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ២. តើអនាម័យមានសារប្រយោជន៍អ្វីខ្លះ?<br>៣. តើការខ្វះអនាម័យអាចបង្កឱ្យមានជំងឺអ្វីខ្លះ?<br>ក្រោយពីពិភាក្សាចប់ អ្នកសម្របសម្រួលផ្តល់ឱកាសក្រុមនីមួយៗ ស្ម័គ្រចិត្តបង្ហាញលទ្ធផលពិភាក្សា មួយក្រុម មួយចម្លើយ ម្តងមួយៗ រួចអ្នកសម្របសម្រួលកត់ចម្លើយលើក្រដាសផ្ទាំងធំ។<br>នៅចុងបញ្ចប់នៃការពិភាក្សាក្រុមតូច អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាងក្រោម។ | |
| ២៥ នាទី | **៣. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗ នូវមេរៀន "**១.២.អនាម័យ**"។ នៅចុងបញ្ចប់នៃការបង្ហាញ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ រួចអ្នកសម្របសម្រួលធ្វើការស្រាយបំភ្លឺបន្ថែម។ | ខ្លឹមសារ មេរៀន ១.២ |

## លំហាត់ទី២. ការពិភាក្សាក្រុមតូច

១. តើអនាម័យមានន័យដូចម្តេច?

២. តើអនាម័យមានសារប្រយោជន៍អ្វីខ្លះ?

៣. តើការខ្វះអនាម័យអាចបង្កឱ្យមានជំងឺអ្វីខ្លះ?

# ប្លង់មេរៀនទី៣

# មគ្គុទ្ទេសក៍សិក្សាសហគមន៍

# ប្លង់មេរៀនទី៣
# មត្តេយ្យសិក្សាសហគមន៍

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច :<br>– កំណត់អំពីអត្ថន័យការអប់រំ<br>– រៀបរាប់អំពីសារប្រយោជន៍នៃការអប់រំកុមារតូច<br>– រៀបរាប់អំពីកត្តាសំខាន់ៗពាក់ព័ន្ធនឹងគុណភាពអប់រំ |
| រយៈពេលសរុប | ១៥០ នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត មេរៀន ១.៣ លំហាត់ទី៣ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ និងការពន្យល់ និងការពិភាក្សា |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ០៥ នាទី | **១. ការផ្ដើមសេចក្ដី**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថាយើងបានសិក្សារួចហើយនូវមេរៀន "**អនាម័យ**" តើមេរៀននោះសិក្សាអំពីអ្វីខ្លះ? បន្ទាប់មក អ្នកសម្របសម្រួលផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយ ឬអ្នកសម្របសម្រួលផ្ដល់ចម្លើយសង្ខេបតែម្ដង។ មេរៀននោះពិពណ៌នាអំពី :<br>– ស្ថានភាពអនាម័យនៅសហគមន៍<br>– ជំងឺមួយចំនួនដែលបណ្ដាលមកពីខ្វះអនាម័យ<br>នៅពេលបញ្ចប់ការសង្ខេបមេរៀននេះ អ្នកសម្របសម្រួលលើកឡើងថា ជាបន្តយើងចូលមេរៀនថ្មីមួយទៀតដែលសិក្សាអំពី "**មត្តេយ្យសិក្សាសហគមន៍**"។ | |
| ០៥ នាទី | **២. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតដោយសួរទៅសិក្ខាកាមថា "**តើការអប់រំមានន័យដូចម្ដេច?**" រួចផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្ដងៗឆ្លើយ បន្ទាប់មក អ្នកសម្របសម្រួលកត់ចម្លើយលើក្រដាសធំ។ ចម្លើយអាចមាន :<br>– ការសិក្សារៀនសូត្រ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | – ការអភិវឌ្ឍសមត្ថភាព កាយ និងបញ្ញា<br>– ការធ្វើឱ្យទទួលបានចំណេះដឹង និងបំណិនជីវិត។<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតបន្តដោយ សួរទៅសិក្ខាកាមថា " **តើការអប់រំសម្រាប់ទាំងអស់គ្នាមានន័យដូចម្តេច?**" រួចផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្តងៗ បន្ទាប់មក អ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– ចលនារបស់ពិភពលោក ដើម្បីឱ្យកុមារ និងយុវជនបានរៀនសូត្រ<br>– មនុស្សគ្រប់រូបអាចចូលរៀន នៅសាលារៀនសាធារណៈ<br>– កុមារ និងយុវជនគ្រប់រូបអាចទទួលបានការរៀនសូត្រគ្រប់គ្នា<br>– ...។ល។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលបំផុសគំនិត សូមពិនិត្យមេរៀនដូចខាងក្រោម។ | |
| ១០ នាទី | **៣. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗនូវមេរៀន "**៣.១.១. ការអប់រំនៅកម្ពុជា ចំណុច ក និង ខ** នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរហើយ អ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ៣.១.១ ចំណុច ក និង ខ |
| ០៥ នាទី | **៤. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតដោយសួរថា " **តើការអប់រំសម្រាប់ទាំងអស់គ្នាមានគោលដៅអ្វីខ្លះ?**"រួចផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្តងៗ ហើយអ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– ពង្រីក កែលម្អការអប់រំ និងថែទាំកុមារតូចឱ្យបានទូលំទូលាយ<br>– ឆ្នាំ២០១៥ កុមារទាំងអស់ បំពេញចប់នូវកាតព្វកិច្ចអប់រំបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ<br>– ការរៀនសូត្ររបស់យុវវ័យទទួលបានឱកាសស្មើភាព និង | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | បណ្តុះបណ្តាលជំនាញចិញ្ចឹមជីវិត(បំណិនជីវិត)<br>– សម្រេចឱ្យបាន៥០% នៅក្នុងកម្រិតអក្ខរកម្មជនពេញវ័យនៅមុនដំណាច់ ឆ្នាំ២០១៥ ពិសេសស្ត្រីភេទ<br>– លុបបំបាត់ភាពខុសគ្នា (វិសមភាព) នៃយេនឌ័រនៅសាលាបឋមសិក្សា និងមធ្យមសិក្សានៅឆ្នាំ២០០៥<br>– កែលម្អលើគ្រប់ទិដ្ឋភាពនៃគុណភាពអប់រំ<br>– ពង្រីក កែលម្អការអប់រំ និងថែទាំកុមារតូចឱ្យបានទូលំទូលាយ<br>នៅចុងបញ្ចប់នៃការពិភាក្សា អ្នកសម្របសម្រួលលើក ឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាង ក្រោម។ | |
| ១០ នាទី | **៥. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗនូវមេរៀន "**១.៣.១. ការអប់រំនៅកម្ពុជា ចំណុច គ**។ នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ១.៣.១ ចំណុច គ |
| ០៥ នាទី | **៦. ការបំផុសគំនិត**<br>បន្ទាប់មកទៀត អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរថា : "**តើការអប់រំមានគោលការណ៍អ្វីខ្លះ?**" រួចផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្តងៗ ហើយអ្នកសម្របសម្រួលកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– ទទួលបានចំណេះដឹង<br>– មានបំណិនជីវិត<br>– ក្លាយជាមនុស្សល្អប្រកបដោយសីលធម៌រស់នៅល្អ<br>– រស់នៅជាមួយគ្នាក្នុងសង្គមប្រកបដោយសុខសន្តិភាព និងសុខដុមរមនា។<br>នៅចុងបញ្ចប់នៃការពិភាក្សា អ្នកសម្របសម្រួលលើក ឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាងក្រោម។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១៥ នាទី | **៧. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗនូវមេរៀន "**១.៣.១. ការអប់រំនៅកម្ពុជា ចំណុច ឃ. និង ង ចំណុច ច និង "១.៣.២.ការអប់រំកុមារតូច ចំណុច ក**។ នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ១.៣.១ ចំណុច ឃ. ង. និងចំណុច ច ១.៣.២. ចំណុច ក |
| ៧៥ នាទី | **៨. ការពិភាក្សាក្រុម**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា រួចចែកសិក្ខាកាមជា៣ក្រុម និងចែកក្រដាសលំហាត់ទី៣ ឱ្យមួយក្រុម មួយច្បាប់។ ក្រុមនីមួយៗ ត្រូវជ្រើសរើសដោយខ្លួនឯងនូវអ្នកសម្របសម្រួលក្រុមមួយនាក់ និងអ្នកឡើងបង្ហាញលទ្ធផលពិភាក្សា មួយនាក់។ ការពិភាក្សាមានរយៈពេល៦០នាទី។ ក្រុមនីមួយៗត្រូវពិភាក្សាប្រធានបទទី១ជាមុនមុននឹងបន្តទៅពិភាក្សាប្រធានបទទី២។ ក្រុមនីមួយៗ ពិភាក្សាលើប្រធានបទដូចខាងក្រោម :<br>**ក្រុមទី១ :**<br>១. តើត្រូវធ្វើដូចម្តេច ដើម្បីជួយជំរុញការអភិវឌ្ឍដល់កុមារតូច?<br>២. តើការអប់រំកុមារតូចមានសារប្រយោជន៍អ្វីខ្លះ?<br>**ក្រុមទី២ :**<br>១. តើការអប់រំកុមារតូចមានសារប្រយោជន៍អ្វីខ្លះ?<br>២. តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យការអប់រំមានគុណភាព?<br>**ក្រុមទី៣ :**<br>១. តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យការអប់រំមានគុណភាព?<br>២. តើត្រូវធ្វើដូចម្តេច ដើម្បីជួយជំរុញការអភិវឌ្ឍកុមារតូច?<br>បន្ទាប់ពីចប់ការពិភាក្សា តំណាងក្រុមនីមួយៗ ឡើងបង្ហាញ និងពន្យល់ពីលទ្ធផលពិភាក្សារបស់ក្រុមខ្លួន។ ការបង្ហាញមានរយៈពេល ៥ នាទី ហើយផ្តល់ឱកាសឱ្យសិក្ខាកាមសួរ និងធ្វើការស្រាយបំភ្លឺបន្ថែម។<br>នៅចុងបញ្ចប់នៃការងារពិភាក្សាក្រុម អ្នកសម្របសម្រួលលើក | លំហាត់ទី៣ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាងក្រោម។ | |
| ១៥ នាទី | **៩. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗនូវមេរៀន "**១.៣.២.ការអប់រំកុមារតូច ចំណុច ខ, គ, និងឃ និង១.៣.៣. កត្តាសំខាន់ៗពាក់ព័ន្ធនឹងគុណភាពនៃការអប់រំ**" នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរហើយ អ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ១.៣.២ និង ១.៣.៣ |

## លំហាត់ទី៣ ការពិភាក្សាក្រុម

ក្រុមទី១ :

១. តើត្រូវធ្វើដូចម្តេច ដើម្បីជួយជំរុញការអភិវឌ្ឍដល់កុមារតូច?

២. តើការអប់រំកុមារតូចមានសារប្រយោជន៍អ្វីខ្លះ?

ក្រុមទី២ :

១. តើការអប់រំកុមារតូចមានសារប្រយោជន៍អ្វីខ្លះ?

២. តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យការអប់រំមានគុណភាព?

ក្រុមទី៣ :

១. តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យការអប់រំមានគុណភាព?

២. តើត្រូវធ្វើដូចម្តេច ដើម្បីជួយជំរុញការអភិវឌ្ឍកុមារតូច?

# ប្លង់មេរៀនទី៤

# សមភាពយេនឌ័រ

# ប្លង់មេរៀនទី៤
# សមភាពយេនឌ័រ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច :<br>– កំណត់ពីនិយមន័យនៃយេនឌ័រ<br>– បង្ហាញពីធាតុសំខាន់ៗ ក្នុងការបញ្ជ្រាបយេនឌ័រ<br>– បង្ហាញពីសមភាពយេនឌ័រក្នុងវិស័យអប់រំ<br>– បង្ហាញអំពីសមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់ |
| រយៈពេលសរុប | ១៩៥ នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត មេរៀន១.៤ លំហាត់ទី៤ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ និង ពិភាក្សាក្រុម |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | | |
| ០៥នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានសិក្សារួចហើយនូវមេរៀន "**មត្តេយ្យសិក្សាសហគមន៍**" តើមេរៀននោះសិក្សាអំពីអ្វីខ្លះ? បន្ទាប់មក អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយ ឬអ្នកសម្របសម្រួលផ្តល់ចម្លើយសង្ខេបតែម្តង។ មេរៀននេះពិពណ៌នាអំពី :<br>– ការអប់រំនៅកម្ពុជា<br>– ការអប់រំកុមារតូច<br>– កត្តាសំខាន់ៗពាក់ព័ន្ធនឹងគុណភាពនៃការអប់រំ<br>បន្ទាប់ពីចប់ ការសង្ខេបមេរៀនមក អ្នកសម្របសម្រួលលើកឡើងថា ជាបន្តយើងចូលមេរៀនមួយទៀតដែលមានចំណងជើងថា "**សមភាពយេនឌ័រ**"។ | |
| ០៥ នាទី | **២. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតដោយសួរទៅសិក្ខាកាមថា | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | **"តើភេទមានន័យដូចម្ដេច?"** បន្ទាប់មក ផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្ដងៗឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ ។ ចម្លើយអាចមាន :<br>– លក្ខណៈខុសគ្នាពីធម្មជាតិដែលកំណត់ស្រី និងប្រុស<br>– ភាពខុសគ្នាអំពីលក្ខណៈជីវសាស្ត្ររវាងស្រី និងប្រុស<br>– . . . ។ល ។<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតបន្ត ដោយសួរទៅសិក្ខាកាមថា **"តើយេនឌ័រមានន័យដូចម្ដេច?"** បន្ទាប់មក ផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្ដងៗឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ ។ ចម្លើយអាចមាន :<br>– ផ្នត់គំនិតដែលសង្គមកំណត់តួនាទីរវាងស្រី និងប្រុស<br>– ការបែងចែកតួនាទី មុខងារ និងសិទ្ធិអំណាចរវាងស្រី និងប្រុស<br>– លក្ខណៈវប្បធម៌ដែលសង្គមប្រកាន់យកចំពោះស្រី និងប្រុស<br>– . . . ។ល ។<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតបន្តដោយសួរទៅសិក្ខាកាមថា **"តើយេនឌ័រ និងភេទខុសគ្នាយ៉ាងដូចម្ដេច?"** បន្ទាប់មក ផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្ដងៗឆ្លើយ រួចកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលបំផុសគំនិត សូមពិនិត្យមេរៀនដូចខាងក្រោម ។ | |
| ១០ នាទី | **៣. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្ដងៗនូវមេរៀន **"១.៤.១. ទស្សនៈទូទៅនៃយេនឌ័រ ចំណុច ក. ខ និង គ"** នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្ដល់ឱកាសឱ្យសួរហើយ អ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម ។ | ខ្លឹមសារមេរៀន ១.៤.១ ចំណុច ក ខ និង គ |
| ០៥ នាទី | **៤. បំផុសគំនិត**<br>បន្ទាប់មកទៀត អ្នកសម្របសម្រួលធ្វើការបំផុសគំនិតបន្ត ដោយ | |

| រយៈពេល | សកម្មភាព | ធនធាន |
| --- | --- | --- |
| | សួរទៅសិក្ខាកាមថា "**តើសមភាពយេនឌ័រមានន័យដូចម្តេច? និង តើសមធម៌យេនឌ័រមានន័យដូចម្តេច?**" រួចផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្តងៗ បន្ទាប់មក អ្នកសម្របសម្រួលកត់ចម្លើយលើក្រដាសផ្ទាំងធំ ។ ចម្លើយអាចមាន :<br>- **សមភាពយេនឌ័រ** : សមភាពយេនឌ័រ គឺសំដៅលើភាពគ្មានការរើសអើងដែលប្រកាន់លើភេទណាមួយ(ប្រុស ឬស្រី) នៅក្នុងការបែងចែកធនធាន ឱកាស សិទ្ធិ ផលប្រយោជន៍ ឬនៅក្នុងការទទួលសេវានានា ។<br>- **សមធម៌យេនឌ័រ** : សមធម៌យេនឌ័រ គឺជាដំណើរការនៃការប្រព្រឹត្តទៅដោយយុត្តិធម៌ទៅលើស្ត្រី និងបុរសសំដៅឱ្យមានសមភាពយេនឌ័រ ។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលនេះ សូមពិនិត្យមេរៀនដូចខាងក្រោម ។ | |
| ១០ នាទី | **៥. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ ពន្យល់ខ្លឹមសារមេរៀន និងផ្តល់ឧទាហរណ៍មួយចំណុចម្តងៗនូវមេរៀន "**១.៤.១. ទស្សនៈទូទៅនៃយេនឌ័រ ចំណុច ឃ** " នៅចុងបញ្ចប់នៃការបង្ហាញមេរៀននេះ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលពន្យល់ និងស្រាយបំភ្លឺបន្ថែម ។ | ខ្លឹមសារមេរៀន ១.៤.១ ចំណុច ឃ |
| ០៥ នាទី | **៦. បំផុសគំនិត**<br>បន្ទាប់មកទៀត អ្នកសម្របសម្រួលធ្វើការបំផុសគំនិតបន្ត ដោយសួរទៅសិក្ខាកាមថា "**តើការបញ្ជ្រាបយេនឌ័រមានន័យដូចម្តេច?**" រួចផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយម្នាក់ម្តងៗ បន្ទាប់មក អ្នកសម្របសម្រួលកត់ចម្លើយលើក្រដាសផ្ទាំងធំ ។ ចម្លើយអាចមាន :<br>- ការបញ្ជ្រាបយេនឌ័រ គឺជាយុទ្ធសាស្ត្រ ឬសកម្មភាពក្នុងការបញ្ចូលនូវបញ្ហា កង្វល់ និងតម្រូវការរបស់ស្ត្រី បុរស និងជនងាយរងគ្រោះទៅក្នុងគោលនយោបាយ ផែនការ កម្មវិធី និង | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | គម្រោងនានា ដោយមានទាំងធនធាន និង មធ្យោបាយសម្រាប់គាំទ្រដល់ដំណើរការអនុវត្តនៃការបញ្ជ្រាប ។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលនេះ សូមពិនិត្យមេរៀនដូចខាងក្រោម ។ | |
| ១០ នាទី | **៧. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ ពន្យល់ខ្លឹមសារមេរៀន និងផ្តល់ឧទាហរណ៍មួយចំណុចម្តងៗនូវមេរៀន "**១.៤.២. ការបញ្ជ្រាបយេនឌ័រ ចំណុច ក និង ខ** នៅចុងបញ្ចប់នៃការបង្ហាញមេរៀននេះ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលពន្យល់ និងស្រាយបំភ្លឺបន្ថែម ។ | ខ្លឹមសារមេរៀន ១.៤.២ ចំណុច ក និងខ |
| ៨៥ នាទី | **៨. ការពិភាក្សាក្រុម**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា រួចចែកសិក្ខាកាមជា៣ក្រុម និងចែកក្រដាសលំហាត់ទី៤ ឱ្យមួយក្រុម មួយច្បាប់ ។ ក្រុមនីមួយៗត្រូវជ្រើសរើសអ្នកសម្របសម្រួលក្រុម មួយនាក់ និងអ្នកឡើងបង្ហាញលទ្ធផលពិភាក្សា មួយនាក់ ។ ការពិភាក្សាមានរយៈពេល ៥៥នាទី ។ ក្រុមនីមួយៗ ពិភាក្សាលើប្រធានបទដូចខាងក្រោម :<br>**ក្រុមទី១ :**<br>១. តើធ្វើយ៉ាងដូចម្តេច ដើម្បីបញ្ចូលបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយ ផែនការ និងស្ថាប័ននៅថ្នាក់ឃុំ សង្កាត់?<br>២. តើធ្វើយ៉ាងដូចម្តេច ដើម្បីពង្រឹងយន្តការ និងបណ្តាញការងារយេនឌ័រដល់ថ្នាក់ឃុំ សង្កាត់ ?<br>**ក្រុមទី២ :**<br>១. ចូរកំណត់សូចនាករសំខាន់ៗ ដើម្បីបង្ហាញអំពីស្ថានភាពសមភាពយេនឌ័រក្នុងវិស័យអប់រំ ?<br>២. តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យមានសមភាពយេនឌ័រក្នុងវិស័យអប់រំ?<br>**ក្រុមទី៣ :**<br>១. ចូរកំណត់សូចនាករសំខាន់ៗ ដើម្បីបង្ហាញអំពីស្ថានភាពសមភាព | លំហាត់ទី៤ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | យេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់ ?<br>២. តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យមានសមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់?<br>បន្ទាប់ពីចប់ការពិភាក្សា តំណាងក្រុមនីមួយៗ ឡើងបង្ហាញ និង ពន្យល់ពីលទ្ធផលពិភាក្សារបស់ក្រុមខ្លួន។ ការបង្ហាញមានរយៈពេល១០ នាទី ហើយផ្ដល់ឱកាសឱ្យសិក្ខាកាមសួរ និងធ្វើការស្រាយបំភ្លឺបន្ថែម។<br>នៅចុងបញ្ចប់នៃការងារពិភាក្សាក្រុម អ្នកសម្របសម្រួលលើក ឡើងថា ដើម្បីឆ្លុះបញ្ចាំងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀន "**១.៤.២. ការបញ្ជ្រាបយេនឌ័រ ១.៤.៣. សមភាពយេនឌ័រក្នុងវិស័យអប់រំ និង ១.៤.៤. សមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់**"។ | |
| ២០ នាទី | **៩. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ ពន្យល់ខ្លឹមសារមេរៀន និង ផ្ដល់ឧទាហរណ៍មួយចំណុចម្ដងៗនូវមេរៀន "**១.៤.២. ការបញ្ជ្រាបយេនឌ័រ ចំណុច ខ.១) ដល់ ខ.៦) ១.៤.៣. សមភាពយេនឌ័រក្នុងវិស័យអប់រំ និង១.៤.៤. សមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់**" នៅចុងបញ្ចប់នៃការបង្ហាញមេរៀននេះ សិក្ខាកាមត្រូវបានផ្ដល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលពន្យល់ និងស្រាយបំភ្លឺបន្ថែម។ | ខ្លឹមសារមេរៀន ១.៤.២. ចំណុច ក និងខ ១.៤.៣ និង ១.៤.៤ |

## លំហាត់ទី៤. ការពិភាក្សាក្រុម

ក្រុមទី១ :

១. តើធ្វើយ៉ាងដូចម្ដេច ដើម្បីបញ្ចូលបញ្ហាយេនឌ័រទៅក្នុងគោលនយោបាយ ផែនការ និងស្ថាប័ននៅថ្នាក់ឃុំ សង្កាត់?

២. តើធ្វើយ៉ាងដូចម្ដេច ដើម្បីពង្រឹងយន្តការ និងបណ្ដាញការងារយេនឌ័រដល់ថ្នាក់ឃុំ សង្កាត់ ?

ក្រុមទី២ :

១. ចូរកំណត់សូចនាករសំខាន់ៗ ដើម្បីបង្ហាញអំពីស្ថានភាពសមភាពយេនឌ័រក្នុងវិស័យអប់រំ ?

២. តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យមានសមភាពយេនឌ័រក្នុងវិស័យអប់រំ?

ក្រុមទី៣ :

១. ចូរកំណត់សូចនាករសំខាន់ៗ ដើម្បីបង្ហាញអំពីស្ថានភាពសមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់ ?

២. តើមានកត្តាអ្វីខ្លះ ដែលធ្វើឱ្យមានសមភាពយេនឌ័រក្នុងការអភិវឌ្ឍន៍ឃុំ សង្កាត់?

# ប្លង់មេរៀនទី៥

# កិច្ចការពារកុមារ

# ប្លង់មេរៀនទី៥

# កិច្ចការពារកុមារ

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច :<br>– ពិពណ៌នាអំពីសិទ្ធិជាមូលដ្ឋានរបស់កុមារ<br>– ពិពណ៌នាអំពីទម្រង់នៃការរំលោភបំពានលើកុមារ<br>– ពិពណ៌នាអំពីកុមារដែលទទួលរងនូវការរំលោភបំពាន |
| រយៈពេលសរុប | ១៦៥ នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត មេរៀន១.៥ លំហាត់ទី៥ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ និង ពិភាក្សាក្រុម |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | | |
| ០៥ នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានសិក្សារួចហើយនូវមេរៀន " សមភាពយេនឌ័រ " តើមេរៀននោះ សិក្សាអំពីអ្វីខ្លះ? បន្ទាប់មក អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយ ឬអ្នកសម្របសម្រួលផ្តល់ចម្លើយសង្ខេបតែម្តង។ មេរៀននេះ ពិពណ៌នាអំពី :<br>– ទស្សនៈទូទៅនៃយេនឌ័រ<br>– ការបញ្ជ្រាបយេនឌ័រ<br>– សមភាពយេនឌ័រក្នុងវិស័យអប់រំ<br>– សមភាពយេនឌ័រក្នុងការអភិវឌ្ឍឃុំ សង្កាត់<br>បន្ទាប់ពីបញ្ចប់ការសង្ខេបមេរៀនមក អ្នកសម្របសម្រួលលើកឡើងថា ជាបន្តយើងចូលមេរៀនមួយទៀតដែលមានចំណងជើងថា "កិច្ចការពារកុមារ"។ | |
| ១០ នាទី | **២. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរទៅសិក្ខាកាមថា | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | "តើសិទ្ធិជាមូលដ្ឋានរបស់កុមារ មានសិទ្ធិអ្វីខ្លះ?" បន្ទាប់មក ផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រម្នាក់ម្តង១ឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– សិទ្ធិក្នុងការរស់រានមានជីវិត<br>– សិទ្ធិក្នុងការអភិវឌ្ឍ<br>– សិទ្ធិទទួលបានការការពារ<br>– សិទ្ធិក្នុងការចូលរួម<br>– ...។ល។<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតបន្តដោយសួរទៅសិក្ខាកាមថា "តើសិទ្ធិជាមូលដ្ឋានរបស់កុមារមានគោលការណ៍អ្វីខ្លះ?" បន្ទាប់មក ផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រម្នាក់ម្តង១ឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– ការមិនរើសអើង<br>– ឧត្តមប្រយោជន៍របស់កុមារ<br>– ការរស់រានមានជីវិត និងការអភិវឌ្ឍ<br>– ការគោរពយោបល់របស់កុមារ<br>– ... ។ល។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលបំផុសគំនិត សូមពិនិត្យមេរៀនដូចខាងក្រោម។ | |
| ១០ នាទី | **៣. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តង១ទូវមេរៀន "**១.៥.១.សិទ្ធិជាមូលដ្ឋានរបស់កុមារ**" នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយ១ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរហើយ អ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ១.៥.១ |
| ១០ នាទី | **៤. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរទៅសិក្ខាកាមថា "**តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកថាជាការរំលោភបំពានលើកុមារ?**" | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | បន្ទាប់មក ផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្ដងៗឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ ។ ចម្លើយអាចមាន :<br>– ការរំលោភបំពានរូបរាងកាយ<br>– ការរំលោភបំពានសតិស្មារតី<br>– ការរំលោភបំពានផ្លូវភេទ<br>– ការមិនយកចិត្តទុកដាក់<br>– ...។ល។<br>អ្នកសម្របសម្រួល ធ្វើការបំផុសគំនិតបន្តដោយសួរទៅសិក្ខាកាមថា "**តើសកម្មភាពអ្វីខ្លះ ដែលចាត់ទុកថា ជាទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ?**" បន្ទាប់មក ផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រម្នាក់ម្ដងៗឆ្លើយ រួចកត់ត្រាចម្លើយលើក្រដាសផ្ទាំងធំ ។ ចម្លើយអាចមាន :<br>– ទាសភាព ឬការអនុវត្តប្រហាក់ប្រហែល<br>– ប្រើប្រាស់ និងអូសទាញកុមារបម្រើក្នុងពេស្យាកម្ម<br>– ប្រើប្រាស់ និងអូសទាញ ឬផ្ដល់ឱ្យកុមារធ្វើសកម្មភាពខុសច្បាប់<br>– ការងារប៉ះពាល់ដល់សុខភាព សុវត្ថិភាព សីលធម៌របស់កុមារ ។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលបំផុសគំនិត សូមពិនិត្យមេរៀនដូចខាងក្រោម ។ | |
| ២០ នាទី | **៥. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្ដងៗ នូវមេរៀន "**១.៥.២.ទម្រង់នៃការរំលោភបំពានលើកុមារ**" នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្ដល់ឱកាសឱ្យសួរហើយ អ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម ។ | ខ្លឹមសារមេរៀន ១.៥.២ |
| ៩០ នាទី | **៦. ការពិភាក្សាក្រុម**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា រួចចែកសិក្ខាកាមជាពក្រុម និងចែកក្រដាសលំហាត់ទី៥ ឱ្យមួយក្រុម មួយច្បាប់ ។ ក្រុមនីមួយៗ ត្រូវជ្រើសរើសអ្នកសម្របសម្រួលក្រុម មួយនាក់ និងឡើងបង្ហាញលទ្ធផលពិភាក្សា មួយនាក់ ។ ការពិភាក្សាមានរយៈពេល ៦០នាទី ។ ក្រុមនីមួយៗ ពិភាក្សាលើប្រធានបទដូចខាងក្រោម : | លំហាត់ទី៥ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | **ក្រុមទី១ :**<br>១. តើអំពើហិង្សាក្នុងគ្រួសារមានន័យដូចម្តេច?<br>២. តើអំពើហិង្សាក្នុងគ្រួសារផ្តល់ផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ ដល់កុមារ?<br>៣. តើត្រូវអន្តរាគមន៍យ៉ាងដូចម្តេច ដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារលើកុមារ?<br>**ក្រុមទី២ :**<br>១. តើអ្វីជាការរំលោភផ្លូវភេទលើកុមារ?<br>២. តើការរំលោភផ្លូវភេទលើកុមារ ផ្តល់ផលប៉ះពាល់អវិជ្ជមានអ្វីខ្លះដល់កុមារ?<br>៣. តើត្រូវអន្តរាគមន៍យ៉ាងដូចម្តេច ដើម្បីដោះស្រាយករណីមានការរំលោភផ្លូវភេទលើកុមារ?<br>**ក្រុមទី៣ :**<br>១. តើសកម្មភាពអ្វីខ្លះ ចាត់ទុកថាជាទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅកម្ពុជា?<br>២. តើពលកម្មកុមារផ្តល់ផលប៉ះពាល់អវិជ្ជមានអ្វីខ្លះដល់កុមារ?<br>៣. តើត្រូវអន្តរាគមន៍យ៉ាងដូចម្តេច ដើម្បីដោះស្រាយករណីពលកម្មធ្ងន់ធ្ងរលើកុមារ?<br>បន្ទាប់ពីចប់ការពិភាក្សា តំណាងក្រុមនីមួយៗ ឡើងបង្ហាញ និងពន្យល់ពីលទ្ធផលពិភាក្សារបស់ក្រុមខ្លួន។ ការបង្ហាញមានរយៈពេល១០នាទី ហើយផ្តល់ឱកាសឱ្យសិក្ខាកាមសួរ និងធ្វើការស្រាយបំភ្លឺបន្ថែម។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាងក្រោម។ | |
| ២០ នាទី | **៧. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗនូវមេរៀន "**១.៥.៣.កុមារដែលទទួលរងនូវការរំលោភបំពាន**" នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរហើយ អ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ១.៥.៣ |

# លំហាត់ទី៥. ការពិភាក្សាក្រុម

**ក្រុមទី១ :**

១. តើអំពើហិង្សាក្នុងគ្រួសារមានន័យដូចម្ដេច?

២. តើអំពើហិង្សាក្នុងគ្រួសារផ្ដល់ផលប៉ះពាល់អវិជ្ជមានអ្វីខ្លះ ដល់កុមារ?

៣. តើត្រូវអន្តរាគមន៍យ៉ាងដូចម្ដេច ដើម្បីដោះស្រាយអំពើហិង្សាក្នុងគ្រួសារលើកុមារ?

**ក្រុមទី២ :**

១. តើអ្វីជាការរំលោភផ្លូវភេទលើកុមារ?

២. តើការរំលោភផ្លូវភេទលើកុមារ ផ្ដល់ផលប៉ះពាល់អវិជ្ជមានអ្វីខ្លះដល់កុមារ?

៣. តើត្រូវអន្តរាគមន៍យ៉ាងដូចម្ដេច ដើម្បីដោះស្រាយករណីមានការរំលោភផ្លូវភេទលើកុមារ?

**ក្រុមទី៣ :**

១. តើសកម្មភាពអ្វីខ្លះ ចាត់ទុកថាជាទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារនៅកម្ពុជា?

២. តើពលកម្មកុមារផ្ដល់ផលប៉ះពាល់អវិជ្ជមានអ្វីខ្លះដល់កុមារ?

៣. តើត្រូវអន្តរាគមន៍យ៉ាងដូចម្ដេច ដើម្បីដោះស្រាយករណីពលកម្មធ្ងន់ធ្ងរលើកុមារ?

# ប្លង់មេរៀនទី៦

# សកម្មភាពឃុំ សង្កាត់

# ក្នុងការអភិវឌ្ឍវិស័យសង្គម

# ប្លង់មេរៀនទី៦

# សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច :<br>– ពិពណ៌នាអំពីការរៀបចំផែនការសកម្មភាព និងថវិកាសម្រាប់អភិវឌ្ឍន៍ផ្នែកសង្គម<br>– ពិពណ៌នាអំពីដំណើរការរៀបចំការផ្សព្វផ្សាយ<br>– ពិពណ៌នាអំពីការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារដល់ស្ត្រីមានផ្ទៃពោះ<br>– ពិពណ៌នាអំពីការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ<br>– ពិពណ៌នាអំពីការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍<br>– ពិពណ៌នាអំពីការរៀបចំវេទិកាលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ<br>– ពិពណ៌នាអំពីការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ |
| រយៈពេលសរុប | ២៨៥ នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត មេរៀនទី៦ លំហាត់ទី៦.១ និងលំហាត់ទី៦.២ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ និងពិភាក្សាក្រុម |

សកម្មភាពសម្របសម្រួលមេរៀន :

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ០៥ នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានសិក្សារួចហើយនូវមេរៀន "កិច្ចការពារកុមារ" តើមេរៀននោះ សិក្សាអំពីអ្វីខ្លះ? បន្ទាប់មក អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយ ឬ អ្នកសម្របសម្រួលផ្តល់ចម្លើយសង្ខេបតែម្តង ។ មេរៀននេះពិពណ៌នាអំពី :<br>- សិទ្ធិជាមូលដ្ឋានរបស់កុមារ<br>- ទម្រង់នៃការរំលោភបំពានលើកុមារ<br>- កុមារដែលទទួលរងនូវការរំលោភបំពាន<br>បន្ទាប់ពីបញ្ចប់ការសង្ខេបមេរៀនមក អ្នកសម្របសម្រួលលើកឡើងថា ជាបន្តយើងចូលមេរៀនមួយទៀតដែលមានចំណងជើងថា "សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម" ។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០ នាទី | **២. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរទៅសិក្ខាកាមថា " **តើធ្វើដូចម្តេច ដើម្បីធានាថា តម្រូវការពាក់ព័ន្ធនឹងសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពាកុមារ ត្រូវបានដាក់បញ្ចូលនៅក្នុងផែនការអភិវឌ្ឍន៍ឃុំ សង្កាត់ និងកម្មវិធីវិនិយោគឃុំ សង្កាត់?**" បន្ទាប់មក ផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្តងៗឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– ការប្រមូលទិន្នន័យ និងព័ត៌មានស្ថានភាពឃុំ សង្កាត់ ដោយការយកចិត្តទុកដាក់លើស្ថានភាពសង្គម<br>– លើកឡើងអំពីតម្រូវការសេវាសង្គម ក្នុងដំណើរការកសាង អ.ផ.ឃ/ស និង ក.វិ.ឃ/ស<br>– ...។ល។<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិតបន្តដោយសួរទៅសិក្ខាកាមថា " **សកម្មភាព(គម្រោង)អ្វីខ្លះ ដែលឃុំ សង្កាត់អាចចាត់ចែង និងអនុវត្តន៍ដោយខ្លួនឯងបាន ដើម្បីឆ្លើយតបនឹងតម្រូវការផ្នែកសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ?**" បន្ទាប់មក ផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្តងៗឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– ការអប់រំផ្សព្វផ្សាយប្រជាពលរដ្ឋ<br>– ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍<br>– ចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ<br>– រៀបចំវេទិកាលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ<br>– គាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះអំពីអំពើហិង្សាក្នុងគ្រួសារ<br>– ... ។ល។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលបំផុសគំនិត សូមពិនិត្យមេរៀនដូចខាងក្រោម ។ | |
| ១០ នាទី | **៣. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗនូវមេរៀន "**២.១.ការរៀបចំផែនការអភិវឌ្ឍន៍ផ្នែកសង្គម**"នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ២.១ |
| ១០០ នាទី | **៤. ការពិភាក្សាក្រុម**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា រួចចែកសិក្ខាកាមជា៣ក្រុម និងចែកក្រដាសលំហាត់ទី៦.១ ឱ្យមួយក្រុម មួយច្បាប់។ ក្រុមនីមួយៗ ត្រូវជ្រើសរើសអ្នកសម្របសម្រួលក្រុម មួយនាក់ និងអ្នកឡើងបង្ហាញលទ្ធផលពិភាក្សា មួយនាក់។ ការពិភាក្សាមានរយៈពេល៧0នាទី។ ក្រុមនីមួយៗ ពិភាក្សាលើប្រធានបទដូចខាងក្រោម :<br>**ក្រុមទី១ :**<br>១. តើការរៀបចំ និងការអនុវត្តការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់អ្នកចូលរួម?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ?<br>២. តើការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារដល់ស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ?<br>**ក្រុមទី២ :**<br>១. តើការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារដល់ស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ?<br>២. តើការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ? | លំហាត់ទី៦.១ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | ក្រុមទី៣ :<br>១. តើការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ?<br>២. តើការរៀបចំ និងការអនុវត្តការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់អ្នកចូលរួម?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ?<br>បន្ទាប់ពីចប់ការពិភាក្សា តំណាងក្រុមនីមួយៗ ឡើងបង្ហាញ និងពន្យល់ពីលទ្ធផលពិភាក្សារបស់ក្រុមខ្លួន។ ការបង្ហាញមានរយៈពេល១០នាទី ហើយផ្តល់ឱកាសឱ្យសិក្ខាកាមសួរ និងធ្វើការស្រាយបំភ្លឺបន្ថែម។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាងក្រោម។ | |
| ៣០ នាទី | **៥. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗ នូវមេរៀន "**២.២.១. ការអនុវត្តការអប់រំផ្សព្វផ្សាយ ២.២.២. ការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារដល់ស្ត្រីមានផ្ទៃពោះ និង ២.២.៣. ចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យ**" នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរហើយ អ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ២.២.១, ២.២.២ និង២.២.៣ |
| ១០០ នាទី | **៦. ការពិភាក្សាក្រុម**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា រួចចែកសិក្ខាកាមជា៣ក្រុម និងចែកក្រដាសលំហាត់ទី៦.២ ឱ្យមួយក្រុម មួយច្បាប់។ ក្រុមនីមួយៗ ត្រូវជ្រើសរើសអ្នកសម្របសម្រួលក្រុម មួយនាក់ និងឡើងបង្ហាញលទ្ធផលពិភាក្សា មួយនាក់។ ការពិភាក្សាមានរយៈពេល៦០នាទី។ ក្រុមនីមួយៗ ពិភាក្សាលើប្រធានបទដូចខាងក្រោម : | លំហាត់ទី៦.២ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | **ក្រុមទី១ :**<br>១. តើការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ទីតាំង និងគ្រូមត្តេយ្យសិក្សាសហគមន៍?<br>ខ).មានជំហានសំខាន់ៗ?អ្វីខ្លះ?<br>២. តើការរៀបចំវេទិកាសាធារណៈ :<br>ក). មានសារប្រយោជន៍អ្វីខ្លះ?<br>ខ). មានជំហានសំខាន់ៗអ្វីខ្លះ?<br>**ក្រុមទី២ :**<br>១. តើការរៀបចំវេទិកាសាធារណៈ :<br>ក). មានសារប្រយោជន៍អ្វីខ្លះ?<br>ខ). មានជំហានសំខាន់ៗអ្វីខ្លះ?<br>២. តើការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារទៅសង្គ្រោះបន្ទាន់ត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ ?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ?<br>**ក្រុមទី៣ :**<br>១. តើការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារទៅសង្គ្រោះបន្ទាន់ត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ ?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ?<br>២. តើការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ត្រូវ :<br>ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ទីតាំង និងគ្រូមត្តេយ្យសិក្សាសហគមន៍?<br>ខ).មានជំហានសំខាន់ៗអ្វីខ្លះ?<br>បន្ទាប់ពីចប់ការពិភាក្សា តំណាងក្រុមនីមួយៗ ឡើងបង្ហាញ និងពន្យល់ពីលទ្ធផលពិភាក្សារបស់ក្រុមខ្លួន។ ការបង្ហាញមានរយៈពេល៥នាទី ហើយផ្ដល់ឱកាសឱ្យសិក្ខាកាមសួរ និងធ្វើការស្រាយបំភ្លឺបន្ថែម។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាងក្រោម ។ | |
| ៣០ នាទី | **៧. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន មួយចំណុចម្តងៗនូវមេរៀន "**២.២.៤.ការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ ២.២.៥. ការរៀបចំវេទិកាលើកកម្ពស់សមភាពយេនឌ័រ និងកិច្ចការពារកុមារ ២.២.៦.ការគាំទ្រមធ្យោបាយ ធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារ និង ២.៣. ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ**" នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម ។ | ខ្លឹមសារមេរៀន<br>២.២.៤ និង<br>២.២.៥<br>២.២.៦ |

# លំហាត់ទី៦.១. ការពិភាក្សាក្រុម

ក្រុមទី១ :

១. តើការរៀបចំ និងការអនុវត្តការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់អ្នកចូលរួម?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

២. តើការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារដល់ស្ត្រីមានផ្ទៃពោះ ដែលក្រីក្រជាងគេត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

ក្រុមទី២ :

១. តើការគាំទ្រមធ្យោបាយធ្វើដំណើរ ឬនិង អាហារដល់ស្ត្រីមានផ្ទៃពោះដែលក្រីក្រជាងគេត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

២. តើការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

ក្រុមទី៣ :

១. តើការចលនាប្រជាពលរដ្ឋសាងសង់ និងប្រើប្រាស់បង្គន់អនាម័យត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

២. តើការរៀបចំ និងការអនុវត្តការអប់រំផ្សព្វផ្សាយដល់ប្រជាពលរដ្ឋត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់អ្នកចូលរួម?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

# លំហាត់ទី៦.២. ការពិភាក្សាក្រុម

ក្រុមទី១ :

១. តើការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ទីតាំង និងគ្រូមត្តេយ្យសិក្សាសហគមន៍?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

២. តើការរៀបចំវេទិកាសាធារណៈ :

ក). មានសារប្រយោជន៍អ្វីខ្លះ?

ខ). មានជំហានសំខាន់ៗអ្វីខ្លះ?

ក្រុមទី២ :

១. តើការរៀបចំវេទិកាសាធារណៈ :

ក). មានសារប្រយោជន៍អ្វីខ្លះ?

ខ). មានជំហានសំខាន់ៗអ្វីខ្លះ?

២. តើការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុង គ្រួសារទៅសង្គ្រោះបន្ទាន់ត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ ?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

ក្រុមទី៣ :

១. តើការគាំទ្រមធ្យោបាយធ្វើដំណើរដល់ជនរងគ្រោះពីអំពើហិង្សាក្នុងគ្រួសារទៅសង្គ្រោះបន្ទាន់ត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ក្រុមគោលដៅ ?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

២. តើការរៀបចំ និងដំណើរការមត្តេយ្យសិក្សាសហគមន៍ត្រូវ :

ក).មានលក្ខណៈវិនិច្ឆ័យអ្វីខ្លះ ក្នុងការកំណត់ទីតាំង និងគ្រូមត្តេយ្យសិក្សាសហគមន៍?

ខ).មានជំហានសំខាន់ៗអ្វីខ្លះ?

# ប្លង់មេរៀនទី៧

# តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

# នៅថ្នាក់ឃុំ សង្កាត់

# ប្លង់មេរៀនទី៧

# តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច :<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់មេឃុំ ចៅសង្កាត់<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់ គ.ក.ន.ក<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់អ្នកដឹកនាំភូមិ<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់ភ្នាក់ងារសេវាសុខភាពសហគមន៍<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់អ្នកសម្របសម្រួលអនាម័យសហគមន៍<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់គ្រូមត្តេយ្យសិក្សាសហគមន៍ |
| រយៈពេលសរុប | ១២៥ នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត មេរៀនទី៧ លំហាត់ទី៧ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ និង ពិភាក្សាក្រុម |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ០៥នាទី | **១. ការផ្តើមសេចក្តី**<br>អ្នកសម្របសម្រួលចាប់ផ្តើមដោយលើកឡើងថា យើងបានសិក្សារួចហើយនូវមេរៀន "**សកម្មភាពឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម**" តើមេរៀននោះសិក្សាអំពីអ្វីខ្លះ? បន្ទាប់មក អ្នកសម្របសម្រួលផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយ ឬអ្នកសម្របសម្រួលផ្តល់ចម្លើយសង្ខេបតែម្តង។ មេរៀននេះ ពិពណ៌នាអំពី :<br>– ការរៀបចំផែនការអភិវឌ្ឍន៍ផ្នែកសង្គម<br>– ការអនុវត្តសកម្មភាពអភិវឌ្ឍន៍ផ្នែកសង្គម<br>– ការតាមដានត្រួតពិនិត្យ និងវាយតម្លៃ<br>បន្ទាប់ពីបញ្ចប់ការសង្ខេបមេរៀនមក អ្នកសម្របសម្រួលលើកឡើងថា ជាបន្តយើងចូលមេរៀនមួយទៀតដែលមានចំណងជើងថា "**យន្តការគាំទ្រការអភិវឌ្ឍផ្នែកសង្គម**"។ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ១០ នាទី | **២. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរទៅសិក្ខាកាមថា " តើនៅថ្នាក់ឃុំ សង្កាត់មានអ្នកពាក់ព័ន្ធណាខ្លះ ដែលអាចចូលរួមគាំទ្រសកម្មភាពលើកកម្ពស់សុខភាព អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ?" បន្ទាប់មកផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្តងៗឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>- ក្រុមប្រឹក្សាឃុំ សង្កាត់<br>- មេឃុំ ចៅសង្កាត់<br>- គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់<br>- អ្នកដឹកនាំភូមិ<br>- អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់<br>- ភ្នាក់ងារសេវាសុខភាពសហគមន៍<br>- អ្នកសម្របសម្រួលអនាម័យសហគមន៍<br>- គ្រូមត្តេយ្យសិក្សាសហគមន៍<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីពិនិត្យអំពីតួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់ យើងសូមចែកក្រុមពិភាក្សា។ | |
| ១០០ នាទី | **៣. ការពិភាក្សាក្រុម**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា រួចចែកសិក្ខាកាមជា៤ក្រុម និងចែកក្រដាសលំហាត់ទី៧ ឱ្យមួយក្រុម មួយច្បាប់។ ក្រុមនីមួយៗ ត្រូវជ្រើសរើសអ្នកសម្របសម្រួលក្រុម មួយនាក់ និងអ្នកឡើងបង្ហាញលទ្ធផលពិភាក្សា មួយនាក់។ ការពិភាក្សាមានរយៈពេល ៦០នាទី។ ក្រុមនីមួយៗ ពិភាក្សាលើប្រធានបទដូចខាងក្រោម :<br>**ក្រុមទី១**<br>១. តើក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម? | លំហាត់ទី៧ |

| រយៈពេល | សកម្មភាព | ធនធាន |
| --- | --- | --- |
| | ២. តើមេឃុំ ចៅសង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>**ក្រុមទី២**<br>១. តើ គ.ក.ន.ក មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>២. តើអ្នកដឹកនាំភូមិមានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>**ក្រុមទី៣**<br>១. តើអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>២. តើភ្នាក់ងារសេវាសុខភាពសហគមន៍មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>**ក្រុមទី៤**<br>១. តើអ្នកសម្របសម្រួលអនាម័យសហគមន៍មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>២. តើគ្រូមត្តេយ្យសិក្សាសហគមន៍មានតួនាទីអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>បន្ទាប់ពីចប់ការពិភាក្សា តំណាងក្រុមនីមួយៗ ឡើងបង្ហាញ និងពន្យល់ ពីលទ្ធផលពិភាក្សារបស់ក្រុមខ្លួន។ ការបង្ហាញមានរយៈពេល ១០ នាទី ហើយផ្តល់ឱកាសឱ្យសិក្ខាកាមសួរ និងធ្វើការស្រាយបំភ្លឺបន្ថែម។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាងក្រោម។ | |
| ២០ នាទី | **៤. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀនមួយចំណុចម្តងៗនូវមេរៀន "៣.១. **តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់**" នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀននីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួលស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ៣.១ |

# លំហាត់ទី៧ ការពិភាក្សាក្រុម

ក្រុមទី១

១. តើក្រុមប្រឹក្សាឃុំ សង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

២. តើមេឃុំ ចៅសង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

ក្រុមទី២

១. តើ គ.ក.ន.ក មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

២. តើអ្នកដឹកនាំភូមិមានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

ក្រុមទី៣

១. តើអ្នកទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ សង្កាត់មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

២. តើភ្នាក់ងារសេវាសុខភាពសហគមន៍មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

ក្រុមទី៤

១. តើអ្នកសម្របសម្រួលអនាម័យសហគមន៍មានតួនាទី និងភារកិច្ចអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

២. តើគ្រូមត្តេយ្យសិក្សាសហគមន៍មានតួនាទីអ្វីខ្លះ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

សំគាល់ : អភិវឌ្ឍន៍ផ្នែកសង្គមផ្តោតលើបញ្ហាសុខភាពមាតា អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារ តែប៉ុណ្ណោះ ។

# ប្លង់មេរៀនទី៨

# តួនាទីនិងភារកិច្ចរបស់អ្នកពាក់ព័ន្ធ

# នៅថ្នាក់រាជធានី ខេត្ត

# ប្លង់មេរៀនទី៨

# តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត

| | |
|---|---|
| គោលបំណង | នៅចុងបញ្ចប់មេរៀនសិក្ខាកាមនឹងអាច :<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់ទីចាត់ការផែនការ និងវិនិយោគ<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់មន្ទីរសុខាភិបាល<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់មន្ទីរអភិវឌ្ឍន៍ជនបទ<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់មន្ទីរអប់រំ យុវជន និងកីឡា<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់មន្ទីរកិច្ចការនារី<br>– ពិពណ៌នាអំពីតួនាទី និងភារកិច្ចរបស់មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា |
| រយៈពេលសរុប | ១៣៥ នាទី |
| សម្ភារៈចាំបាច់ | ក្រដាសផ្ទាំងធំ ហ្វឺត ស្កុត មេរៀនទី៨ លំហាត់ទី៨ |
| វិធីសាស្ត្រ | ការបំផុសគំនិត ការបង្ហាញ ការពន្យល់ និង ពិភាក្សាក្រុម |
| សកម្មភាពសម្របសម្រួលមេរៀន : | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| ០៥នាទី | **១. ការផ្ដើមសេចក្ដី**<br>អ្នកសម្របសម្រួលចាប់ផ្ដើមដោយលើកឡើងថា យើងបានសិក្សារួចហើយនូវមេរៀន "តួនាទីរបស់អ្នកពាក់ព័ន្ធនៅថ្នាក់ឃុំ សង្កាត់" តើមេរៀននោះសិក្សាអំពីអ្វីខ្លះ? បន្ទាប់មក អ្នកសម្របសម្រួលផ្ដល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តឆ្លើយ ឬអ្នកសម្របសម្រួលផ្ដល់ចម្លើយសង្ខេបតែម្ដង។ មេរៀននេះ ពិពណ៌នាអំពី :<br>– តួនាទី និងភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់<br>– តួនាទី និងភារកិច្ចរបស់មេឃុំ ចៅសង្កាត់<br>– តួនាទី និងភារកិច្ចរបស់ គ.ក.ន.ក<br>– តួនាទី និងភារកិច្ចរបស់អ្នកដឹកនាំភូមិ<br>– តួនាទី និងភារកិច្ចរបស់អ្នកទទួលបន្ទុកកិច្ចការនារី និងកុមារ<br>– តួនាទី និងភារកិច្ចរបស់ភ្នាក់ងារសេវាសុខភាពសហគមន៍ | |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | – តួនាទី និងភារកិច្ចរបស់អ្នកសម្របសម្រួលអនាម័យសហគមន៍<br>– តួនាទី និងភារកិច្ចរបស់គ្រូមត្តេយ្យសិក្សាសហគមន៍<br>បន្ទាប់ពីចប់ ការសង្ខេបមេរៀនមក អ្នកសម្របសម្រួលលើកឡើងថា ជាបន្តយើងចូលមេរៀនមួយទៀតដែលមានចំណងជើងថា **"តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត"**។ | |
| ១០ នាទី | **២. ការបំផុសគំនិត**<br>អ្នកសម្របសម្រួលធ្វើការបំផុសគំនិត ដោយសួរទៅសិក្ខាកាមថា **" តើនៅថ្នាក់រាជធានី ខេត្តមានអ្នកពាក់ព័ន្ធណាខ្លះ ដែលចូលរួមគាំទ្រសកម្មភាពលើកកម្ពស់សុខភាព អនាម័យ មត្តេយ្យសិក្សាសហគមន៍ សមភាពយេនឌ័រ និងកិច្ចការពារកុមារនៅឃុំ សង្កាត់?"** បន្ទាប់មក ផ្តល់ឱកាសឱ្យសិក្ខាកាមស្ម័គ្រចិត្តម្នាក់ម្តង១ឆ្លើយ រួចកត់ចម្លើយលើក្រដាសផ្ទាំងធំ។ ចម្លើយអាចមាន :<br>– ទីចាត់ការផែនការ និងវិនិយោគ<br>– មន្ទីរសុខាភិបាល<br>– មន្ទីរអភិវឌ្ឍន៍ជនបទ<br>– មន្ទីរអប់រំ យុវជន និងកីឡា<br>– មន្ទីរកិច្ចការនារី<br>– មន្ទីរសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទា<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីពិនិត្យអំពីតួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធនៅថ្នាក់រាជធានី ខេត្ត យើងសូមចែកក្រុមពិភាក្សា។ | |
| ១០០ នាទី | **៣. ការពិភាក្សាក្រុម**<br>អ្នកសម្របសម្រួលពន្យល់អំពីកិច្ចការដែលត្រូវពិភាក្សា រួចចែកសិក្ខាកាមជា៣ក្រុម និងចែកក្រដាសលំហាត់ទី៨ ឱ្យមួយក្រុម មួយច្បាប់។ ក្រុមនីមួយ១ ត្រូវជ្រើសរើសអ្នកសម្របសម្រួលក្រុម មួយនាក់ និងអ្នកឡើងបង្ហាញលទ្ធផលពិភាក្សា មួយនាក់។ ការពិភាក្សាមានរយៈពេល ៦០នាទី។ ក្រុមនីមួយ១ ពិភាក្សាលើប្រធានបទដូចខាងក្រោម : | លំហាត់ទី៨ |

| រយៈពេល | សកម្មភាព | ធនធាន |
|---|---|---|
| | **ក្រុមទី១**<br>១. តើទីចាត់ការផែនការ និងវិនិយោគមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>២. តើមន្ទីរសុខាភិបាលមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>**ក្រុមទី២**<br>១. តើមន្ទីរអភិវឌ្ឍន៍ជនបទមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ក្នុងការអភិវឌ្ឍន៍ផ្នែកសង្គម?<br>២. តើមន្ទីរអប់រំ យុវជន និងកីឡាមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បី ជួយឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>**ក្រុមទី៣**<br>១. តើមន្ទីរកិច្ចការនារីមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>២. មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានតួនាទី និង ភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម?<br>បន្ទាប់ពីចប់ការពិភាក្សា តំណាងក្រុមនីមួយៗ ឡើងបង្ហាញ និង ពន្យល់ពីលទ្ធផលពិភាក្សារបស់ក្រុមខ្លួន។ ការបង្ហាញមានរយៈពេល ១០នាទី ហើយផ្តល់ឱកាសឱ្យសិក្ខាកាមសួរ និងធ្វើការស្រាយបំភ្លឺបន្ថែម។<br>នៅចុងបញ្ចប់នៃការបំផុសគំនិត អ្នកសម្របសម្រួលលើកឡើងថា ដើម្បីឆ្លុះបញ្ចាំងនឹងលទ្ធផលពិភាក្សា សូមពិនិត្យមេរៀនដូចខាងក្រោម។ | |
| ២០ នាទី | **៤. ការបង្ហាញ និងពន្យល់ខ្លឹមសារ**<br>បន្ទាប់មក អ្នកសម្របសម្រួលបង្ហាញ និងពន្យល់ខ្លឹមសារមេរៀន មួយចំណុចម្តងៗនូវមេរៀន "៣.១.តួនាទី និងភារកិច្ចរបស់អ្នកពាក់ព័ន្ធ នៅថ្នាក់រាជធានី ខេត្ត" នៅចុងបញ្ចប់នៃការបង្ហាញខ្លឹមសារមេរៀន នីមួយៗ សិក្ខាកាមត្រូវបានផ្តល់ឱកាសឱ្យសួរ ហើយអ្នកសម្របសម្រួល ស្រាយបំភ្លឺពន្យល់បន្ថែម។ | ខ្លឹមសារមេរៀន ៣.២ |

## លំហាត់ទី៨ ការពិភាក្សាក្រុម

**ក្រុមទី១**

១. តើទីចាត់ការផែនការ និងវិនិយោគមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម?

២. តើមន្ទីរសុខាភិបាលមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

**ក្រុមទី២**

១. តើមន្ទីរអភិវឌ្ឍន៍ជនបទមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ ក្នុងការអភិវឌ្ឍន៍ផ្នែកសង្គម?

២. តើមន្ទីរអប់រំ យុវជន និងកីឡាមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម?

**ក្រុមទី៣**

១. តើមន្ទីរកិច្ចការនារី មានតួនាទី និង ភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ ក្នុងការអភិវឌ្ឍផ្នែកសង្គម?

២. តើមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាមានតួនាទី និងភារកិច្ចអ្វីខ្លះ ដើម្បីជួយឃុំ សង្កាត់ក្នុងការអភិវឌ្ឍផ្នែកសង្គម?